**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ :....០៣៧.....បទ.ប្រ.ក..

" ...ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព "

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០៨

# ប្រ ក ា ស

## ស្ដីអំពីការគ្រប់គ្រងបរិក្ខារវិទ្យុគមនាគមន៍ និង ថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ

### រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្ដីពីការរៀបចំ និង ការ ប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី៥ ខែមិនា ឆ្នាំ១៩៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្ដីពីប្រៃសណីយ៍ និង ទូរគមនាគន៍
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ/បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០២ ស្ដីពីការកែសំរួល និងបំពេញបន្ថែមនាយកដ្ឋានមួយចំនួននៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ/បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៣ ស្ដីពីការតម្លើង នាយកដ្ឋានរដ្ឋបាលនិងបណ្ដុះបណ្ដាល ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍



កាច់ជ្រុងវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ

ទូរស័ព្ទ : (៨៥៥) ២៣-៧២៤៨០៩/៤២៦៥១០

ទូរសារ : (៨៥៥) ២៣-៤២៦៩៩២/៤២៦០១១/៤២៦៥៤១

- បានឃើញសេចក្តីសំរេចលេខ ១៥៤ សសរ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីឋានានុក្រមគ្រប់គ្រងតម្លៃ

## សំរេច

ប្រការ១ : កំណត់ថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ និង ថ្លៃសេវាសំរាប់បរិក្ខារវិទ្យុគមនាគមន៍ ដូចមានឧបសម្ព័ន្ធទី១ ដល់ឧបសម្ព័ន្ធទី៣ ភ្ជាប់នឹងសេចក្តីប្រកាសនេះ ។

ប្រការ២ : ប្រកាសស្តីពីការគ្រប់គ្រងបរិក្ខារវិទ្យុគមនាគមន៍និងថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ លេខ ២៧២ បទ.ប្រក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៣ ប្រកាសស្តីពីការកែសម្រួល និងបន្ថែមលើការគ្រប់គ្រងបរិក្ខារវិទ្យុគមនាគមន៍និងថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ លេខ ២០០បទ.ប្រក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៤ និង រួមទាំងប្រកាសទាំងឡាយណា ដែលមានពីមុន ហើយមានន័យផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៣ : អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍ និង ទូរគមនាគមន៍ អធិការដ្ឋាន គ្រប់នាយកដ្ឋានពាក់ព័ន្ធ និងគ្រប់មន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ ខេត្ត -ក្រុងក្រោមឱវាទក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ត្រូវទទួលបន្ទុកអនុវត្តតាមតួនាទី ភារកិច្ចនូវប្រកាសនេះ ឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

ប្រការ៤ : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

សូ-ខុន

**កន្លែងទទួល**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  " ដើម្បីជ្រាបជាពតិមាន "
- ដូចប្រការ៣ " ដើម្បីអនុវត្ត "
- ឯកសារ - កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១
## ថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ

| | | |
|---|---|---|
| ១- | **វិទ្យុប្រភេទ** MF | **រៀល** |
| | **ក/វិទ្យុប្រភេទ MF ចល័ត** | |
| | - ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿង១ | ១០,០០០ |
| | - ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿង១ មុនពេលតំលើងលើនាវា | ៣០,០០០ |
| | - ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿង១ មុនពេលតំលើងលើដីគោក | ២៥,០០០ |
| | - តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ឋបនភ័ណ្ឌមួយគ្រឿង១ ចំពោះអានុភាព X watt និង បន្ទារប្រេកង់ស៍ Y KHz | ៦០,០០០+៣,០០០X+៧,០០០Y |
| | **ខ/វិទ្យុប្រភេទ MF អចល័ត** | |
| | - ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿង១ | ១០,០០០ |
| | - ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿង១ មុនពេលតំលើង | ២៥,០០០ |
| | - តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ឋបនភ័ណ្ឌមួយគ្រឿង១ ចំពោះអានុភាព X watt និង បន្ទារប្រេកង់ស៍ Y KHz | ៦០,០០០+២,០០០X+៧,០០០Y |
| ២- | **វិទ្យុប្រភេទ** HF (PTT : Push To Talk) | **រៀល** |
| | *សំគាល់:* ចំពោះស្ថានទូតក្នុងការទាក់ទងផ្ទាល់ជាមួយប្រទេសរបស់ខ្លួន ត្រូវបានអនុគ្រោះដោយមិនគិតថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ ។ | |
| | **ក/វិទ្យុប្រភេទ HF ចល័ត** | |
| | - ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿង១ | ១០,០០០ |
| | - ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿង១ មុនពេលតំលើងលើនាវា | ៣០,០០០ |
| | - កាពិនិត្យឋបនភ័មួយគ្រឿង១ មុនពេលតំលើងលើដីគោក | ២៥,០០០ |
| | - តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ឋបនភ័ណ្ឌមួយគ្រឿង១ ចំពោះអានុភាព X watt និង បន្ទារប្រេកង់ស៍ Y KHz | ៦០,០០០+៣,០០០X +៧,០០០Y |

**ខ/វិទ្យុប្រភេទ HF អចល័ត**

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿងៗ ១០,០០០
- កាពិនិតឋបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង ២៥,០០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ឋបនភ័ណ្ឌមួយគ្រឿងៗ

ចំពោះអានុភាព X watt និង បន្ទាប្រេក្វង់សី Y KHz ៦០,០០០+១,៥០០X+៧,០០០Y

៣- **វិទ្យុប្រភេទ** VHF (PTT : Push To Talk) **រៀល**

**ក/វិទ្យុប្រភេទ VHF ចល័តទូទាំងក្នុងផ្ទៃប្រទេស**

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿងៗ ១០,០០០
- កាពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង :

  ចំពោះវិទ្យុទាក់ទងតូចៗកាន់ជាប់នឹងដៃ (walkie talkie) ១០,០០០

  ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើនាវា ២០,០០០

  ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើដី ១៥,០០០
- តម្លៃអាជ្ញាប័ណ្ណប្រាំឆ្នាំ សម្រាប់ឋបនភ័ណ្ឌមួយគ្រឿងៗ

ចំពោះអានុភាព X watt និង បន្ទាប្រេក្វង់សី Y KHz ២៥,០០០+១,៨០០X+៨០០Y

**ខ/វិទ្យុប្រភេទ VHF ចល័តក្នុងខេត្ត/ក្រុង**

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿងៗ ១០,០០០
- ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង :

  ចំពោះវិទ្យុទាក់ទងតូចៗកាន់ជាប់នឹងដៃ (walkie talkie) ១០,០០០

  ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើនាវា ២០,០០០

  ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនោលើដី ១៥,០០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ឋបនភ័ណ្ឌមួយគ្រឿងៗ

ចំពោះអានុភាព X watt និង បន្ទាប្រេក្វង់សី Y KHz ២៥,០០០+១,៥០០X+៨០០Y

**គ/វិទ្យុប្រភេទ VHF អច័ត**

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿងៗ ១០,០០០
- ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង ១៥,០០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ឋបនភ័ណ្ឌមួយគ្រឿងៗ

ចំពោះអានុភាព X wat និង បន្ទាប្រេក្វង់សី Y KHz ២៥,០០០+១,០០០X+៨០០Y

**៤- វិទ្យុប្រភេទ UHF** (PTT : Push To Talk) **រៀល**

**ក/វិទ្យុប្រភេទ UHF ចល័តទូទាំងក្នុងផ្ទៃប្រទេស**

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿងៗ ១០,០០០
- ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង :

ចំពោះវិទ្យុទាក់ទងតូចៗកាន់ជាប់នឹងដៃ ( walkie talkie ) ១០,០០០

ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើនាវា ២០,០០០

ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើដី ១៥,០០០

- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ឋបនភ័ណ្ឌមួយគ្រឿងៗ

ចំពោះអានុភាព X watt និង បន្ទារប្រេកង់ស៍ Y KHz ២៥,០០០+១,៥០០X+៨០០Y

**ខ/ វិទ្យុប្រភេទ UHF ចល័តក្នុងខេត្ត/ក្រុង**

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿងៗ ១០,០០០
- ការពិនិត្យឋបនភ័ណ្ឌមួយៗ មុនពេលតំលើង :

ចំពោះវិទ្យុទាក់ទងតូចៗកាន់ជាប់នឹងដៃ ( walkie talkie ) ១០,០០០

ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើនាវា ២០,០០០

ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើដី ១៥,០០០

- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ឋបនភ័ណ្ឌមួយគ្រឿងៗ

ចំពោះអានុភាព X watt និង បន្ទារប្រេកង់ស៍ Y KHz ២៥,០០០+១,៣០០X+៨០០Y

**គ/វិទ្យុប្រភេទ UHF អចល័ត**

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿងៗ ១០,០០០
- ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង ១០,០០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ឋបនភ័ណ្ឌមួយគ្រឿងៗ

ចំពោះអានុភាព X watt និង បន្ទារប្រេកង់ស៍ Y KHz ២៥,០០០+១,០០០X+៨០០Y

**៥- វិទ្យុប្រភេទ TLMRS, Mobile Cellular Phone, Wireless Fixed Phone USD**

*សំគាល់* ចំពោះបរិក្ខាតូចៗ ឬ កាន់ជាប់នឹងដៃពុំចាំបាច់មានអាជ្ញាប័ណ្ណទេ ។

- ការទទួលពិនិត្យពាក្យសុំដំណើរការ ៥០
- ការពិនិត្យឋបនភ័ណ្ឌសំរាប់ដំណើរការ ១០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ដំណើរការនៃប្រព័ន្ធទូទាំងប្រទេស

ចំពោះអានុភាព X watt និង បន្ទារប្រេកង់ស៍ Y KHz ១០០ + ៣០X + ៣Y

**៦- វិទ្យុជាប្រព័ន្ធបញ្ជូនទិន្នន័យ រឺជា Wireless Access Network** **USD**

**ក/ ករណីធម្មតា**

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿងៗ ៣០
- ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង ៥០

**ក-១/ សំរាប់ Analoge**

- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ឋបនភ័ណ្ឌមួយគ្រឿងៗ

ចំពោះអានុភាព X watt និង បន្ទារប្រេក្វង់ Y KHz ៥០០ + ១.៨X + ១.៣Y

**ក-២/ សំរាប់ Digital**

- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ឋបនភ័ណ្ឌមួយគ្រឿងៗ

| | |
|---|---|
| ល្បឿនបញ្ជូនតូចជាង ឬ ស្មើ 128 Kbps | ៤០០ |
| ល្បឿនបញ្ជូនធំជាង 128 Kbps ឬ ស្មើ 512 Kbps | ៤៥០ |
| ល្បឿនបញ្ជូនធំជាង 512 Kbps ឬ ស្មើ 2 Mbps | ៥០០ |
| ល្បឿនបញ្ជូនធំជាង 2 Mbps | ៥៥០ |

**ខ/ ករណីសំរាប់ ISP (WiFi, WiMax, ...)**

- ការទទួលពិនិត្យពាក្យសុំដំណើរការ Base Station ៥០
- ការពិនិត្យឋបនភ័ណ្ឌសំរាប់ដំណើរការ Base Station ១០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ដំណើរការនៃប្រព័ន្ធទូទាំងប្រទេស

ចំពោះបន្ទារប្រេក្វង់ស៊ី Y KHz ៥០០ + ០.២៥Y

(ចំពោះ Subscriber របស់ ISP ពុំចាំបាច់មានអាជ្ញាប័ណ្ណទេ)

**គ/ ករណី Satellite Broadband Internet (SBI)**

- ការទទួលពិនិត្យពាក្យសុំដំណើរការ Base Station ៥០
- ការពិនិត្យឋបនភ័ណ្ឌសំរាប់ដំណើរការ Base Station ១០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ដំណើរការនៃប្រព័ន្ធទូទាំងប្រទេស

| | |
|---|---|
| ចំពោះបន្ទារប្រេក្វង់ស៊ី Y KHz (Ka Band) | ៥០០ + ០.៤Y |
| ចំពោះបន្ទារប្រេក្វង់ស៊ី Y KHz (Ku Band) | ៥០០ + ០.៣Y |

(ចំពោះ Subscriber របស់ SBI ពុំចាំបាច់មានអាជ្ញាប័ណ្ណទេ)

| | | | |
|---|---|---|---|
| **៧- វិទ្យុគ្រប់ប្រភេទជា MICROWAVE** | | | **USD** |
| - ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនិមួយៗ | | | ៣០ |
| - ការពិនិត្យបរិក្ខាររួចមួយគ្រឿងៗ មុនពេលតំលើង | | | ៥០ |
| - តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំសម្រាប់បរិក្ខាររួចមួយគ្រឿងៗ ដែលមានល្បឿនបញ្ជូន: | | | |
| **ក/ បង់ប្រេកង់ស៊ីចាប់ពី ១.៥ GHz ទៅ ៦ GHz** | | | |
| ចាប់ពី | ២Mbps តែតូចជាង | ៨Mbps | ៦០០ |
| ចាប់ពី | ៨Mbps តែតូចជាង | ៣៤Mbps | ៧៥០ |
| ចាប់ពី | ៣៤Mbps តែតូចជាង | ១៤០Mbps | ៩០០ |
| ចាប់ពី | ១៤០Mbps លើងទៅ | | ១,០០០ |
| **ខ/ បង់ប្រេកង់ស៊ីចាប់ពី ៧ GHz ទៅ ១៥ GHz** | | | |
| ចាប់ពី | ២Mbps តែតូចជាង | ៨Mbps | ៥០០ |
| ចាប់ពី | ៨Mbps តែតូចជាង | ៣៤Mbps | ៦៥០ |
| ចាប់ពី | ៣៤Mbps តែតូចជាង | ១៤០Mbps | ៨៥០ |
| ចាប់ពី | ១៤០Mbps លើងទៅ | | ៩៥០ |
| **គ/ បង់ប្រេកង់ស៊ីធំជាង ១៥ GHz លើងទៅ** | | | |
| ចាប់ពី | ២Mbps តែតូចជាង | ៨Mbps | ៤៥០ |
| ចាប់ពី | ៨Mbps តែតូចជាង | ៣៤Mbps | ៦០០ |
| ចាប់ពី | ៣៤Mbps តែតូចជាង | ១៤០Mbps | ៧៥០ |
| លើសពី | ១៤០Mbps លើងទៅ | | ៩០០ |

| | |
|---|---|
| **៨- បរិក្ខាទំនាក់ទំនងក្នុងករណីមានការអនុញ្ញាតិពិសេស** | **USD** |
| **ក/ វិទ្យុទាក់ទងអន្តរជាតិ (PTT: Push To Talk)** | |
| - ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនិមួយៗ | ១០ |
| - ការពិនិត្យបរិក្ខាររួចមួយគ្រឿងៗ មុនពេលតំលើង | ២០ |
| - តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់វិទ្យុមួយគ្រឿងៗ | |
| ចំពោះអានុភាព X watt និង បន្ទារប្រេកង់ស៊ី Y KHz | ២០ + 0.៨X + ២Y |
| **ខ/ VSAT សំរាប់សំលេង ឬ ទិន្នលេខ (សំរាប់ប្រើប្រាស់ផ្ទាល់ខ្លួន)** | |
| - ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនិមួយៗ | ៥០ |
| - ការពិនិត្យបរិក្ខាររួចមួយគ្រឿងៗ មុនពេលតំលើង | ១០០ |
| - តម្លៃសួយសារប្រចាំខែ (Royalty Fee) | ២,០០០ |
| - តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ស្ថានីយ៍មួយគ្រឿង | ៤,០០០ |

**គ/ VSAT សំរាប់បញ្ជូនរូបភាពទូរទស្សន៍ ( ព្រឹត្តិការណ៍ពិសេស)**

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខានិមួយៗ ៥០
- ការពិនិត្យវាស់បនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង ១០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំថ្ងៃ សម្រាប់ស្ថានីយ៍មួយគ្រឿង ១,០០០

**ឃ/ VSAT សំរាប់សម្លេង ឬ ទិន្នលេខ (សំរាប់ប្រតិបត្តិករ)**

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនិមួយៗ ៥០
- ការពិនិត្យវាស់បនភ័ណ្ឌមួយគ្រឿងៗមុនពេលតម្លើង ១០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំសំរាប់ស្ថានីយ៍មួយគ្រឿងៗ ១,៥០០

**ង/ VSAT សំរាប់បញ្ជូនរូបភាពទូរទស្សន៍ក្នុង ឬ ក្រៅប្រទេស**

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនិមួយៗ ៥០
- ការពិនិត្យវាស់បនភ័ណ្ឌមួយគ្រឿងៗ មុនពេលតម្លើង ១០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សំរាប់ស្ថានីយ៍មួយគ្រឿងៗ ១,០០០

## ៩- វិទ្យុផ្សាយសំលេង USD

- ការទទួលពិនិត្យពាក្យសុំបើកស្ថានីយ៍និមួយៗ ៣០
- ការពិនិត្យវាស់បនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង ៥០

**ក/ តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំលើវិទ្យុប្រភេទ AM ; SW**

ចំពោះអានុភាព X watt និង បន្ទារប្រេកង់សឺ Y KHz ១០០ + 0.0៥X + ២0Y

**ខ/ តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំលើវិទ្យុប្រភេទ FM**

ចំពោះអានុភាព X watt និង បន្ទារប្រេកង់សឺ Y KHz ១០០ + 0.0៥X + ២Y

## ១០- ទូរទស្សន៍ USD

- ការទទួលពិនិត្យពាក្យសុំបើកស្ថានីយ៍និមួយៗ ៣០
- ការពិនិត្យវាស់បនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង ៥០

**ក/ តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ចំពោះទូរទស្សន៍ប្រភេទ VHF**

ចំពោះអានុភាព X watt និង បន្ទារប្រេកង់សឺ Y KHz ១០០ + 0.0៥X + 0.0៥Y

**ខ/ តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ចំពោះទូរទស្សន៍ប្រភេទ UHF**

ចំពោះអានុភាព X watt និង បន្ទារប្រេកង់សឺ Y KHz ១០០ + 0.0៥X + 0.0៤Y

**គ/ តម្លៃអាជ្ញាបណ្ណ័ប្រចាំឆ្នាំ ចំពោះទូរទស្សន៍ប្រភេទ MMDS**

ចំពោះអានុភាព X watt និង បន្ទារប្រេកង់សឺ Y KHz ១០០ + 0.0៥X + 0.0៣Y

**១១- វិទ្យុអាម៉ាទ័រ** USD

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ ៥
- ការពិនិត្យបច្ចេកទេសមួយគ្រឿង១ មុនពេលតំលើង ១០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ស្ថានីយ៍មួយគ្រឿង១ ២៥

**១២- អ៊ិនម៉ាសាត INMARSAT** USD

**ក/ អ៊ិនម៉ាសាតគ្រប់ប្រភេទចល័តឬអចល័ត ឬ តាំងជាប់នៅលើនាវា**

១- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនិមួយ១ ៣០

២- ការពិនិត្យបច្ចេកទេសមួយគ្រឿង១ មុនពេលតំលើង ១០០

៣- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សំរាប់ស្ថានីយ៍មួយគ្រឿង១ ២០០

៤- តម្លៃប្រើប្រាស់ស្មើនឹងតម្លៃរបស់ស្ថានីយ៍អ៊ិម៉ាសាតលើដី +១៥%

៥- ប្រាក់កក់សំរាប់ទូទាត់តម្លៃនៃការប្រើប្រាស់អ៊ិនម៉ាសាត១គ្រឿង ១,០០០

ចំពោះអ៊ិនម៉ាសាតតាំងជាប់នៅលើនាវា អតិថិជនអាចមិនជ្រើសរើសយកក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ធ្វើជាអាជ្ញាធរទូទាត់ (Accounting Authority) សំរាប់ទូទាត់តម្លៃជាមួយស្ថានីយ៍អ៊ិនម៉ាសាតលើដី។ ក្នុងករណីនេះចំនុច ៤និង៥មិនគិតទេ។

**ខ/ ចំពោះអ៊ិនម៉ាសាតគ្រប់ប្រភេទ ដែលចុះឈ្មោះនៅបរទេសហើយនាំចូលមកប្រើប្រាស់នៅលើទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា** USD

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនិមួយ១ ៣០
- ការពិនិត្យបច្ចេកទេសមួយគ្រឿង១ មុនពេលតំលើង ៥០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សំរាប់ស្ថានីយ៍មួយគ្រឿង១ ៤០០

**១៣- ល័ក្ខខ័ណ្ឌនៃការផ្តត់ផ្គង់សេវា**

ក្រសួងប.ទជំរុញការអភិវឌ្ឍន៍ និងការប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍ដែលសមស្របតាមលក្ខណៈបច្ចេកទេស។ ក្នុងករណីដែលប្រព័ន្ធទូរគមនាគមន៍ពុំទាន់មាន ក្រសួងប.ទបានអនុញ្ញាតិឱ្យមានការប្រើប្រាស់វិទ្យុគមនាគមន៍ ហើយបានកំណត់តម្លៃទាបសំរាប់ប្រេកង់ស៍នោះ។ ប៉ុន្តែក្នុងករណីដែលប្រព័ន្ធបណ្តាញទូរគមនាគមន៍មានរួចហើយ តម្លៃរលកអាកាសវិទ្យុសេវានោះនឹងមានកំរិតមកជាធម្មតាវិញ។ ដូច្នេះហើយតម្លៃរលកអាកាសវិទ្យុខាងលើនេះអាចមានកំរិតខ្ពស់ ឬទាប ទៅតាមករណីនីមួយ១។ ក្នុងករណីដែលអាចធ្វើអោយប៉ះពាល់ដល់ សេវានៃបណ្តាញទូរគមនាគមន៍ខ្សែកាប ក្រសួងប.ទអាចមិនអនុញ្ញាតិឱ្យប្រើប្រាស់ប្រព័ន្ធវិទ្យុគមនាគមន៍នោះ។

១៣.១ ចំពោះអង្គការមនុស្សធម៌អន្តរជាតិ ឬ អង្គការមិនមែនរដ្ឋាភិបាល ដែលមានកិច្ចព្រមព្រៀងក្របខ័ណ្ឌក្នុងការអនុគ្រោះពន្ធ ទូទៅជាមួយព្រះរាជាណាចក្រកម្ពុជា គឺត្រូវបានអនុគ្រោះ៧០% នៃតម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ។

១៣.២ ចំពោះ Two-Way Radio បន្ទារប្រេកង់នៃវិទ្យុមានពីរផ្នែកគឺផ្សាយនិងទទួល ។ ក្នុងករណីនេះ ការគិតតម្លៃប្រេកង់ គឺគិតតែមួយផ្នែកដែលជាបរិក្ខារផ្សាយ ។

១៣.៣ អានុភាពផ្សាយគិតតាមអានុភាពអតិបរិមានៃបរិក្ខារ ។

១៣.៤ រយៈពេលកំណត់នៃអាជ្ញាប័ណ្ណមានមួយឆមាស ឬ មួយឆ្នាំ ។ ក្នុងករណីអាជ្ញាប័ណ្ណមានរយៈពេលមួយឆមាស តម្លៃអាជ្ញាប័ណ្ណនោះស្មើនឹងពាក់កណ្តាលនៃតម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំនៃបរិក្ខារនោះ ។

១៣.៥ ការសុំប្រើប្រាស់បន្តដោយគ្មានប្រការណាមួយប្រែប្រួលនៅក្នុងអាជ្ញាប័ណ្ណចាស់ គឺត្រូវគិតតែតម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សំរាប់អាជ្ញាប័ណ្ណថ្មី ។

១៣.៦ អ្នកកោសលុប ឬ ក្លែងបន្លំដោយប្រការណាមួយនៅលើអាជ្ញាប័ណ្ណ ត្រូវទទួលទោសតាមច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ។

## ឧបសម្ព័ន្ធទី២

## ច្បាប់ទទួលស្គាល់បរិក្ខាវិទ្យុគមនាគមន៍ (Type Approval for Each Model)

## និង តម្លៃជាដុល្លារ USD

| | | |
|---|---|---|
| ទូរស័ព្ទចល័ត | ២,០០០ | (no expiry date) |
| ទូរសារ (Facsimile machine) | ១,៥០០ | (no expiry date) |
| បមាណី ( PABX ) | ១,៥០០ | (no expiry date) |
| ទូរស័ព្ទធម្មតា ឬ Wireless Phone | ១,៥០០ | (no expiry date) |
| ផេជើង (Pager) | ១,០០០ | (no expiry date) |
| បរិក្ខារវិទ្យុគមនាគមន៍ដទៃផ្សេងទៀត | ១,០០០ | (no expiry date) |
| ភ្នាក់ងារនាំចូលបរិក្ខារវិទ្យុគមនាគមន៍ | ៨០០ | (no expiry date) |
| ច្បាប់រដ្ឋបាលនាំចូលបរិក្ខារវិទ្យុគមនាគមន៍សំរាប់ការងារផ្ទាល់ខ្លួន | ១០០ | (each time) |
| វិញ្ញាបនប័ត្រប្រចាំឆ្នាំ សំរាប់នាំចូល/លក់/ជួសជុល បរិក្ខារវិទ្យុគមនាគមន៍ | ១០០ | |
| វិញ្ញាបនប័ត្រប្រចាំឆ្នាំ សំរាប់ លក់/ជួសជុល បរិក្ខារវិទ្យុគមនាគមន៍ | ៥០ | |

ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ ០៣៧ បទ.ប្រក ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ២០០៨

## ឧបសម្ព័ន្ធទី៣

## ការផាកពិន័យ

**សំគាល់ : ប្រាក់ពិន័យពុំមែនជាប្រាក់សំរាប់ទូទាត់តម្លៃអាជ្ញាប័ណ្ណទេ ។**

១ ការប្រើប្រាស់បរិក្ខារវិទ្យុគមនាគមន៍មួយគ្រឿងទោះចល័តក្តី អចល័តក្តី ហើយគ្មានអាជ្ញាប័ណ្ណ ប្រាក់ពិន័យស្មើនឹង តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំនៃបរិក្ខារនោះគុណនឹង ០.៥ដង ។

២ ការផ្លាស់ប្តូររលកអាកាសវិទ្យុ ដោយគ្មានការអនុញ្ញាតពីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ប្រាក់ពិន័យស្មើនឹង តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំនៃបរិក្ខារនោះគុណនឹង ០.៤ដង ។

៣ ការផ្លាស់ប្តូរថបនភ័ណ្ឌវិទ្យុគមនាគមន៍ ឬ ទីតាំងថបនភ័ណ្ឌវិទ្យុគមនាគមន៍ដោយគ្មាន ការអនុញ្ញាតពីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ប្រាក់ពិន័យស្មើនឹង តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំនៃបរិក្ខារនោះគុណនឹង ០.៣ដង ។

៤ ការប្រើប្រាស់អាជ្ញាប័ណ្ណហួសពេលកំណត់ ប្រាក់ពិន័យស្មើនឹង តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ នៃបរិក្ខារនោះគុណនឹង ០.២ដង ។